អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ....០០២.........អ.ស.ហ.ប្រក

# ប្រកាស
## ស្តីពី
## សេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់

- បានឃើញប្រកាសលេខ ៥៦៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ
- បានឃើញប្រកាសលេខ ០២០ អ.ស.ហ.ប្រក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការកំណត់ប្រភព និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់និយ័តករគណនេយ្យនិងសវនកម្ម
- បានឃើញប្រកាសលេខ ០១១ អ.ស.ហ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ ស្តីពីការស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេស
- បានឃើញប្រកាសលេខ ០១៩ អ.ស.ហ.ប្រក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- យោងតាមការស្នើរបស់និយ័តករគណនេយ្យនិងសវនកម្ម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីប្រភេទនិងកម្រៃសេវាសាធារណៈ បែបបទ នីតិវិធី និងការចាត់ចែងចំណូលពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃដំណើរការរបស់ **ន.គ.ស.**។

## ជំពូកទី២
## ប្រភេទ និងកម្រៃសេវាសាធារណៈ

**ប្រការ២.-**

ប្រភេទ និងកម្រៃសេវាសាធារណៈរបស់ **ន.គ.ស.** ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា | សុពលភាព |
|---|---|---|---|---|
| ១ | ការប្រើថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងការថែទាំ (Maintenance) | | | |
| | ១.១. សហគ្រាស | ៤០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| | ១.២. អង្គភាពមិនស្វែងរកប្រាក់ចំណេញ | ២០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| ២ | សេវាទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ | | | |
| | ២.១.សហគ្រាសជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ៣០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| | ២.២.សហគ្រាសមិនជាប់កាតព្វកិច្ចដាក់របាយ-ការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ២០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |

| | | | | |
|---|---|---|---|---|
| | ២.៣.អង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១០០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| | ២.៤.អង្គភាពមិនស្វែងរកប្រាក់ចំណេញមិនជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ៦០ ០០០ រៀល | ៣០ថ្ងៃ | ១ឆ្នាំ |
| ៣ | សេវាស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | | | |
| | ៣.១.រយៈពេលមិនលើស៣០ថ្ងៃ | ២០០ ០០០ រៀល | ៥ថ្ងៃ | ១លើក |
| | ៣.២.រយៈពេលចាប់ពី៣១ថ្ងៃ ទៅដល់ ៦០ថ្ងៃ | ១៥ ០០០ រៀល/ថ្ងៃ | ៥ថ្ងៃ | ១លើក |
| ៤ | សេវាស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងារសវនកម្មឯករាជ្យ | | | |
| | ៤.១.រយៈពេលមិនលើស៣០ថ្ងៃ | ១០០ ០០០ រៀល | ៥ថ្ងៃ | ១លើក |
| | ៤.២.រយៈពេលចាប់ពី៣១ថ្ងៃ ទៅដល់ ៩០ថ្ងៃ | ៥ ០០០ រៀល/ថ្ងៃ | ៥ថ្ងៃ | ១លើក |
| | ៤.៣.រយៈពេលចាប់ពី៩១ថ្ងៃ ទៅដល់ ១២០ថ្ងៃ | ១០ ០០០ រៀល/ថ្ងៃ | ៥ថ្ងៃ | ១លើក |
| | ៤.៤.រយៈពេលចាប់ពី១២១ថ្ងៃ ទៅដល់១៥០ថ្ងៃ | ២០ ០០០ រៀល/ថ្ងៃ | ៥ថ្ងៃ | ១លើក |
| ៥ | លិខិតអនុញ្ញាតបដិប្បញ្ញត្តិក្នុងការដាក់របាយ-ការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ១ ០០០ ០០០ រៀល | ៣០ថ្ងៃ | ១លើក |
| ៦ | លិខិតអនុញ្ញាតផ្លាស់ប្តូរការិយបរិច្ឆេទគណនេយ្យ | ១ ០០០ ០០០ រៀល | ៣០ថ្ងៃ | ១លើក |
| ៧ | ការស្នើសុំផ្លាស់ប្តូរគណនីប្រើប្រាស់ក្នុងប្រព័ន្ធ E-Filing | ៤០ ០០០ រៀល | ១៥ថ្ងៃ | ១លើក |
| ៨ | កែតម្រូវព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ | ១០០ ០០០ រៀល | ១៥ថ្ងៃ | ១លើក |
| ៩ | លិខិតបញ្ជាក់បច្ចុប្បន្នភាពព័ត៌មានសហគ្រាស | ២០០ ០០០ រៀល | ៣០ថ្ងៃ | ១លើក |
| ១០ | ការប្រឹក្សាយោបល់អំពីការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម | ៤០០ ០០០ រៀល | ភ្លាមៗ | ១ម៉ោង |
| ១១ | សេវាប្រឹក្សាលើវិវាទក្នុងនាមជាអ្នកសម្របសម្រួល | ១០០ ០០០ រៀល | ភ្លាមៗ | ១ម៉ោង |
| ១២ | ការស្នើសុំអនុញ្ញាតផ្តល់សេវាជម្រះបញ្ជី | ៤០០ ០០០ រៀល | ១៥ថ្ងៃ | អាស្រ័យលើសុពលភាពអាជ្ញាបណ្ណ |
| ១៣ | ការធ្វើបច្ចុប្បន្នភាពព័ត៌មានក្រុមហ៊ុន ដែលប៉ះពាល់ដល់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម | ២០០ ០០០ រៀល | ១៥ថ្ងៃ | ១លើក |
| ១៤ | ការស្នើសុំព្យួរអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យដោយស្ម័គ្រចិត្ត (នីតិបុគ្គល) | ២០០ ០០០ រៀល | ចំនួន១៥ថ្ងៃ (ថ្ងៃធ្វើការ) | ១លើក |
| ១៥ | ការស្នើសុំព្យួរអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មដោយស្ម័គ្រចិត្ត (នីតិបុគ្គល) | ៤០០ ០០០ រៀល | ចំនួន១៥ថ្ងៃ (ថ្ងៃធ្វើការ) | ១លើក |

| | | | | |
|---|---|---|---|---|
| ១៦ | សិក្សាសំណុំឯកសារ ក្នុងការស្នើសុំបញ្ឈប់ការប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម | ៤០០ ០០០ រៀល | ចំនួន៣០ថ្ងៃ (ថ្ងៃធ្វើការ) | ១លើក |
| ១៧ | ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ឬកែប្រែព័ត៌មានលើសន្លឹកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម | ៤០០ ០០០ រៀល | ចំនួន១៥ថ្ងៃ (ថ្ងៃធ្វើការ) | ១លើក |
| ១៨ | ស្នើសុំពន្យារពេលផ្តល់របាយការណ៍ស្ថានភាពរបស់ក្រុមហ៊ុនមក **ន.គ.ស.** ជាអាទិ៍ ចំនួនបុគ្គលិក និងទីតាំងការិយាល័យក្រុមហ៊ុន (ក្នុងករណីមានការប្រែប្រួលឬផ្លាស់ប្តូរ) | ២០០ ០០០ រៀល | ចំនួន១៥ថ្ងៃ (ថ្ងៃធ្វើការ) | រយៈពេល ១ខែ |
| ១៩ | ស្នើសុំពន្យារពេលផ្តល់របាយការណ៍ស្ថិតិលម្អិតនៃអតិថិជននិងរបាយការណ៍ផ្សេងទៀតប្រចាំឆមាសនិងប្រចាំឆ្នាំមក **ន.គ.ស.** | ២០០ ០០០ រៀល | ចំនួន១៥ថ្ងៃ (ថ្ងៃធ្វើការ) | រយៈពេល ១ខែ |
| ២០ | ស្នើសុំពន្យារពេលផ្តល់របាយការណ៍តម្លាភាពប្រចាំឆ្នាំមក **ន.គ.ស.** ចំពោះសហគ្រាសទទួលខុសត្រូវជាសាធារណៈ | ២០០ ០០០ រៀល | ចំនួន១៥ថ្ងៃ (ថ្ងៃធ្វើការ) | រយៈពេល ១ខែ |
| ២១ | ស្នើសុំពន្យារពេលរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការបណ្តុះបណ្តាលប្រចាំឆ្នាំរបស់ខ្លួនមក **ន.គ.ស.** ជារៀងរាល់ឆ្នាំដើម្បីពិនិត្យ និងវាយតម្លៃ | ២០០ ០០០ រៀល | ចំនួន១៥ថ្ងៃ (ថ្ងៃធ្វើការ) | រយៈពេល ១ខែ |

**ប្រការ៣.-**

ការពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវផ្តល់ជូនមិនលើសពីរយៈពេល៦០(ហុកសិប)ថ្ងៃ និងការពន្យារពេលក្នុងការបញ្ចប់ការងារសវនកម្មឯករាជ្យ ត្រូវផ្តល់ជូនមិនលើសពីរយៈពេល១៥០(មួយរយហាសិប)ថ្ងៃ។ ប៉ុន្តែ **ន.គ.ស.** អាចផ្តល់ការពន្យារពេលលើសពីការកំណត់នៅក្នុងវាក្យខណ្ឌទី១ នៃប្រការ៣នេះបាន ប្រសិនបើសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលស្នើសុំនោះមានមូលហេតុសមស្រប ឬមានតម្រូវការចាំបាច់ តែត្រូវស្នើសុំជាលាយលក្ខណ៍អក្សរ និងទទួលបានការសម្រេចជាមុនពី **ន.គ.ស.**។ ក្នុងករណីមានការឯកភាពតាមការស្នើសុំ កម្រៃសេវាត្រូវគណនាដោយផ្អែកតាមរយៈពេលដែលស្នើសុំពន្យារបន្ថែមនោះ គឺ ៤០,០០០(បួនម៉ឺន)រៀលក្នុងមួយថ្ងៃ។

**ប្រការ៤.-**

ការគណនាកម្រៃសេវាស្នើសុំពន្យារពេលបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងការងារសវនកម្មឯករាជ្យ ត្រូវគិតតាមរបៀបដូចខាងក្រោម៖

**<u>ឧទាហរណ៍ទី១</u>៖**

សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលដាក់លិខិតស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំក្នុងរយៈពេល៦០ថ្ងៃ ត្រូវគិតរយៈពេលមូលដ្ឋានតម្លៃសេវាមិនលើសពី៣០ថ្ងៃ បូក៣០ថ្ងៃ ដែលជាចំនួនថ្ងៃនៃការស្នើសុំពន្យារពេល ដោយគណនាដូចខាងក្រោម៖

(២០០០០០ រៀល) + (៣០ x ១៥០០០ រៀល) = ៦៥០០០០ រៀល

ដូចនេះ កម្រៃសេវាត្រូវបង់គឺ ៦៥០ ០០០ រៀល។

<u>ឧទាហរណ៍ទី២៖</u>

សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលដាក់លិខិតស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងារសវនកម្មឯករាជ្យក្នុងរយៈពេល១៥០ថ្ងៃ ត្រូវគិតរយៈពេលមូលដ្ឋានតម្លៃសេវាមិនលើស៣០ថ្ងៃ បូក ៦០ថ្ងៃ បូក៣០ថ្ងៃ បូក៣០ថ្ងៃ ដែលជាចំនួនថ្ងៃនៃការស្នើសុំពន្យារពេល ដោយគណនាដូចខាងក្រោម៖

(១០០០០០ រៀល) + (៦០ x ៥០០០ រៀល) + (៣០ x ១០០០០ រៀល) + (៣០ x ២០០០០ រៀល) = ១៣០០០០០ រៀល

ដូចនេះ កម្រៃសេវាត្រូវបង់គឺ ១ ៣០០ ០០០ រៀល។

## ជំពូកទី៣
## ការផ្សព្វផ្សាយ និងការផ្តល់សេវាគាំទ្រ

**ប្រការ៥.-**

**ន.គ.ស.** ត្រូវបិទផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈនូវប្រកាសនេះ នៅនឹងកន្លែងផ្តល់សេវា ឬតាមបណ្តាញព័ត៌មាននានា។

**ន.គ.ស.** ត្រូវរៀបចំទីកន្លែងផ្តល់សេវា និងមានមន្ត្រីប្រចាំការនៅទីកន្លែងដែលបានកំណត់ជាក់លាក់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

**ន.គ.ស.** ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដាសេវា ឬមានការយកម្រៃសេវាលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

## ជំពូកទី៤
## នីតិវិធីនៃការស្នើសុំ និងការបង់កម្រៃសេវាសាធារណៈ

**ប្រការ៦.-**

បុគ្គលស្នើសុំសេវាសាធារណៈរបស់ **ន.គ.ស.** អាចស្នើសុំតាមរយៈទីតាំងផ្ទាល់របស់ **ន.គ.ស.** ឬតាមរយៈគេហទំព័ររបស់ **ន.គ.ស.**។

**ប្រការ៧.-**

បុគ្គលស្នើសុំសេវាសាធារណៈរបស់ **ន.គ.ស.** ត្រូវបង់កម្រៃសេវាសាធារណៈចូលគណនីរបស់ **ន.គ.ស.**។

## ជំពូកទី៥
## ការគ្រប់គ្រងចំណូលពីសេវាសាធារណៈ

**ប្រការ៨.-**

**ន.គ.ស.** មានភារកិច្ចប្រមូលចំណូល គ្រប់គ្រង និងចាត់ចែងចំណូលពីសេវាសាធារណៈដែលប្រមូលបានស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ៩._**

ប្រកាសលេខ ០០១ អ.ស.ហ.ប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០._**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣ ៨ ១០ ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា គ.ស.២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព និងសមាសភាពក្រុមប្រឹក្សានៃ **អ.ស.ហ.**
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ